01072036

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 03 / 2015
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

E319/7/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥

**ផ្ញើជូន៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** លោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំឱ្យកែតម្រូវកំហុសជាក់ស្តែងមួយនៅក្នុងសេចក្តីសម្រេច E319/7

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើពីមេធាវីការពារក្តី ខៀវ សំផន ដែលសុំឱ្យកែតម្រូវកំហុសជាក់ស្តែងមួយក្នុងកថាខណ្ឌ ៧ នៃសេចក្តីសម្រេច E319/7 (ឯកសារ E319/7/1 កថាខណ្ឌ ១ ដល់ ៦)។ សំណៅជាភាសាអង់គ្លេសនៃសេចក្តីសម្រេចនេះចង្អុលបង្ហាញថា មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ទៅនឹងកថាខណ្ឌ ៥(ក) នៃសេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីនីតិវិធីដែលបានស្នើឡើងដើម្បីប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៣ និង ០០៤[1] (ឯកសារ E319/7 កថាខណ្ឌ ៧ និង ជើងទំព័រ

---

[1] សូមមើល ឯកសារ E319/2 (“នីតិវិធីដែលបានស្នើដោយសហព្រះរាជអាជ្ញាអន្តរជាតិ”)។ កថាខណ្ឌ ៥(ក) ស្នើសុំមិនឱ្យឱ្យលើកឡើងនូវកំណត់ហេតុលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីពីសំណុំរឿង ០០៣ និង ០០៤ នៅក្នុងសវនាការ

១៦)។ មេធាវីការពារក្ដី ខៀវ សំផន លើកឡើងថា ការពិតលក្ខខណ្ឌនៃការជំទាស់របស់ខ្លួនគឺពាក់ព័ន្ធនឹងកថាខណ្ឌ ៥(ង) នៃនីតិវិធីដែលបានស្នើដោយសហព្រះរាជអាជ្ញាអន្តរជាតិ ដោយសំអាងទៅលើសំណៅជាភាសាបារាំងនៃកិច្ចប្រជុំរៀបចំសវនាការដែលបានធ្វើនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ (ឯកសារ E319/7/1 កថាខណ្ឌ ៥)។ ពុំមានភាគីណាមួយឆ្លើយតបទៅនឹងសំណើសុំនេះទេ។

២. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា កថាខណ្ឌ ៧ នៃសេចក្ដីសម្រេច E319/7 បានសំអាងទៅលើសំណៅជាភាសាអង់គ្លេសនៃប្រតិចារឹក ដែលបានចង្អុលបង្ហាញថា មេធាវីការពារក្ដី ខៀវ សំផន បានជំទាស់ទៅនឹងកថាខណ្ឌ ៥.១ នៃនីតិវិធីដែលបានស្នើដោយសហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ E1/244.1/Corr.3 ទំព័រ ១៣ (ភាសាអង់គ្លេស))។ ដោយគ្មានកថាខណ្ឌ ៥.១ នៅក្នុងនីតិវិធីដែលបានស្នើដោយសហព្រះរាជអាជ្ញាអន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងយល់ថា ការជំទាស់របស់មេធាវីការពារក្ដី ខៀវ សំផន សំដៅទៅរកកថាខណ្ឌ ៥(ក) (ឯកសារ E319/7 ជើងទំព័រ ១៦)។ បន្ទាប់មក សំណៅជាភាសាអង់គ្លេសនៃប្រតិចារឹកត្រូវបានកែតម្រូវដើម្បីធ្វើឲ្យបានសុក្រឹតទៅតាមសំណៅជាភាសាបារាំង ដែលចង្អុលបង្ហាញថា មេធាវីការពារក្ដី ខៀវ សំផន លើកឡើងពីលក្ខខណ្ឌនៃការជំទាស់ពាក់ព័ន្ធនឹងការអនុវត្តដែលបានរៀបរាប់ក្នុងកថាខណ្ឌ ៥(ង) នៃនីតិវិធីដែលបានស្នើដោយសហព្រះរាជអាជ្ញាអន្តរជាតិ (ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ១៨ (ភាសាអង់គ្លេស))។

៣. ពាក់ព័ន្ធនឹងចំណុចខាងលើ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កថាខណ្ឌ ៧ និងជើងទំព័រ ១៦ នៃ សេចក្ដីសម្រេច E319/7 មានកំហុសមួយពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការជំទាស់ដែលមេធាវីការពារក្ដី ខៀវ សំផន បានលើកឡើង ចំពោះនីតិវិធីដែលបានស្នើដោយសហព្រះរាជអាជ្ញាអន្តរជាតិ។ ផ្អែកទៅលើសិទ្ធិអំណាចក្នុងការកែតម្រូវកំហុសដែលអាចមានក្នុងសេចក្ដីសម្រេចដែលខ្លួនបានចេញ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កំហុសមួយនេះ សក្ដិសមនឹងធ្វើការកែតម្រូវ ហើយការកែតម្រូវនេះមិនប៉ះពាល់ដល់លទ្ធផលនៃសេចក្ដីសម្រេចដែលបានចេញឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើរបស់មេធាវីការពារក្ដី ខៀវ សំផន ហើយធ្វើការកែតម្រូវសេចក្ដីសម្រេចដូចខាងក្រោម៖

---

សាធារណៈ: តែគ្រាន់តែផ្តល់អត្តសញ្ញាណឯកសារទាំងនេះតាមរយៈឯកសារសំណុំរឿង ០០២ ដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង។

កថាខណ្ឌ ៧ នៃសេចក្ដីសម្រេច E319/7 ត្រូវសរសេរដូចតទៅនេះ៖

> មិនមានការដាក់សារណាតបជាលាយលក្ខណ៍អក្សរទៅនឹងនីតិវិធីដែលបានស្នើឡើងនេះឡើយ។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ ដែលបានធ្វើឡើងនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងសួរអំពីការជំទាស់ណាមួយទៅនឹងនីតិវិធីដែលបានស្នើឡើងនោះ មេធាវីការពារក្ដី នួន ជា មិនបានបញ្ជាក់អំពីជំហររបស់ខ្លួនឡើយ។ មេធាវីការពារក្ដី ខៀវ សំផន បានកត់សម្គាល់ថា នីតិវិធីដែលបានស្នើឡើងនោះ គឺស្រដៀងគ្នាទៅនឹងការអនុវត្តដែលមេធាវីការពារក្ដីបានប្ដឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១ និង**បានលើកឡើងនូវលក្ខខណ្ឌរបស់ខ្លួនចំពោះការផ្ដល់ទៅឱ្យសាក្សីនូវចម្លើយពីមុនៗរបស់ពួកគេ និងផ្ដល់ឱកាសឱ្យពួកគេមានលទ្ធភាពពិនិត្យលើចម្លើយទាំងនោះមុនពេលមកផ្ដល់សក្ខីកម្មក្នុងតុលាការ។** ~~មានជំទាស់ទៅនឹងបទប្បញ្ញត្តិដែលបានស្នើឡើង ដែលហាមឃាត់មិនឱ្យមានការយោងទៅលើកំណត់ហេតុនៃការស្ដាប់ចម្លើយដែលជាឯកសារសម្ងាត់ មានប្រភពដើមពីសំណុំរឿង ០០៣ ឬ ០០៤ នៅក្នុងអំឡុងពេលសវនាការជាសាធារណៈឡើយ។~~ មេធាវីការពារក្ដី ខៀវ សំផន ពុំបានបញ្ជាក់ពីការជំទាស់ផ្សេងទៀតឡើយ។

ជើងទំព័រ ១៦ ត្រូវសរសេរដូចតទៅនេះ៖

> ប្រតិចារឹក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ១៨ (ភាសាអង់គ្លេស) **ដោយយោង** ~~មេធាវីការពារក្ដី ខៀវ សំផន បានជំទាស់~~ទៅ កថាខណ្ឌ “៥ **(ង)**~~១~~” នៃនីតិវិធីដែលបានស្នើឡើង។ ~~ផ្ទុយទៅវិញ តាមការសន្និដ្ឋាន មេធាវីការពារក្ដី ខៀវ សំផន ចង់សំដៅទៅលើកថាខណ្ឌ “៥(ក)” នៃនីតិវិធីដែលបានស្នើឡើង។~~

៤. អង្គជំនុំជម្រះសាលាដំបូងនឹងចេញសំណៅដែលបានកែតម្រូវនៃសេចក្ដីសម្រេច ដែលនឹងអាចរកបាននៅក្នុងឯកសារ E319/7 និង E319/7_corr។

៥. អនុស្សរណៈនេះជាការឆ្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E319/7/1។